MGCC
MASSACHUSETTS GROWTH CAPITAL CORPORATION
EMPOWERING SMALL BUSINESS

# កម្មវិធីជំនួយថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពឌីជីថល

## ហេតុអ្វីបានជាយើងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីជំនួយថវិកានេះ?

MGCC ប្តេជ្ញាជួយអាជីវកម្មខ្នាតតូចនៅរដ្ឋ Massachusetts
តាមរយៈការផ្តល់ហិរញ្ញប្បទាននិងជំនួយក្នុងការគ្រប់គ្រង
លទ្ធភាពក្នុងទទួលបានធនធានសម្រាប់អាជីវកម្ម
និងសេវាកម្មបុគ្គលដើម្បីកំណត់និងបង្កើតដំណោះស្រាយដែលសមនឹងតម្រូវការរបស់ពួកគេ។កម្មវិធីជំនួយថវិកានេះផ្តល់មូលនិធិដែលនឹងជួយដល់អាជីវកម្មខ្នាតតូចក្នុងការអភិវឌ្ឍសមត្ថភាពឌីជីថលរបស់ពួកគេ (ជាពិសេសផ្តោតលើប្រតិបត្តិការ តម្រូវការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ទីផ្សារឌីជីថល និងការទាក់ទងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម)
តាមរយៈការគាំទ្រពីអ្នកផ្តល់ជំនួយបច្ចេកទេសសម្រាប់អាជីវកម្មខ្នាតតូច (Small Business Technical Assistance, SBTA) របស់យើង។

## តើកម្មវិធីជំនួយថវិកានេះគឺជាអ្វី?

កម្មវិធីផ្តល់ជំនួយនេះនឹងផ្តល់ថវិការហូតដល់ $5,000 (តិចជាង $250 ដែលបានបង់ទៅឱ្យអ្នកឧបត្ថម្ភ SBTA)
ដើម្បីបន្តគម្រោងនានាដែលនឹងជួយដល់អាជីវកម្មខ្នាតតូចរបស់បុគ្គលដែលមានការលំបាកផ្នែកសង្គមនិងសេដ្ឋកិច្ច អភិវឌ្ឍសមត្ថភាពឌីជីថលរបស់ពួកគេ។អ្នកផ្តល់សេវា SBTA
នឹងឧបត្ថម្ភនិងជួយដល់អាជីវកម្មខ្នាតតូចក្នុងការចូលនិងបំពេញដំណើរការដាក់ពាក្យស្នើសុំ។ម្ចាស់អាជីវកម្មខ្នាតតូចដែលបានដាក់ពាក្យស្នើសុំ
នឹងឆ្លងកាត់ដំណើរការវាយតម្លៃតម្រូវការឌីជីថលរបស់ពួកគេហើយធ្វើការជាមួយអ្នកជំនាញដែលមានសមត្ថភាពដើម្បីបង្កើតដំណោះស្រាយតាមរយៈគម្រោងអភិវឌ្ឍឌីជីថលដោយមានជំនួយពីអ្នកឧបត្ថម្ភ SBTA របស់ពួកគេ។

## តើអ្នកណាខ្លះមានសិទ្ធិដាក់ពាក្យស្នើសុំបាន?

ត្រូវតែជា **អាជីវកម្មខ្នាតតូច** ដែល៖

- **មាន** មូលដ្ឋាននៅរដ្ឋ Massachusetts ជាមួយទីតាំងហាងក្នុងរដ្ឋ (មិនមែនជាហាងដែលធ្វើតែអាជីវកម្មតាមអ៊ីនធឺណិត) ឬមុខហាងដែលដំណើរការនៅក្នុងរដ្ឋ Massachusetts ។
- **គឺ** ជួលបុគ្គលិកពេញម៉ោងឬសមមូល (FTE employee) ពី 1 ទៅ 20 នាក់
- **គឺ** ប្រភពចំណូលចម្បងរបស់ម្ចាស់អាជីវកម្ម
- **មាន** ប្រាក់ចំណូលប្រចាំឆ្នាំមិនលើសពី $2,500,000
- **បានបញ្ចប់** និងបញ្ជូនការពិនិត្យវាយតម្លៃឌីជីថលទៅកាន់អ្នកឧបត្ថម្ភ SBTA របស់ពួកគេដើម្បីត្រួតពិនិត្យ
- **ត្រូវ** បានជ្រើសរើសដោយអ្នកផ្តល់ជំនួយបច្ចេកទេសតាមរយៈកម្មវិធីជំនួយបច្ចេកទេសសម្រាប់អាជីវកម្មខ្នាតតូច (Small Business Technical Assistance Program) របស់ MGCC
- **បាន** ធ្វើអាជីវកម្មយ៉ាងហោចណាស់មួយឆ្នាំនៅពេលដាក់ពាក្យស្នើសុំ
- **គឺ <u>មិនមែន</u>** ជាអង្គការមិនស្វែងរកប្រាក់ចំណេញ អង្គការមិនរកប្រាក់ចំណេញ ឬអង្គការសប្បុរស
- **គឺ <u>មិនមែន</u>** ជាអាជីវកម្មដែលផ្គត់ផ្គង់សេវាកម្មឌីជីថលដល់អាជីវកម្មផ្សេងទៀត (ឧទាហរណ៍ រចនា/អភិវឌ្ឍន៍គេហទំព័រ SEO ការសរសេរកម្មវិធី)
- **គឺ <u>មិនមែនជា</u>** អាជីវកម្មជួញដូរផ្តាច់មុខ (franchise) ដែលមានទីតាំងច្រើនជាង 2 កន្លែង រួមទាំងទីតាំងនិងអាជីវកម្មដែលគ្រប់គ្រងដោយឯកជន (អាជីវកម្មជួញដូរផ្តាច់មុខដែលមានរហូតដល់ 2 ទីតាំងនឹងត្រូវយកមកពិចារណា)
- **គឺ <u>មិនមែនជា</u>** អាជីវកម្មជួល/លក់អចលនទ្រព្យ
- **គឺ <u>មិនមែនជា</u>** អ្នកបញ្ចុះបញ្ចូលខាងនយោបាយ
- **គឺ <u>មិនមែនជា</u>** អាជីវកម្មទាក់ទងនឹងកញ្ឆា

<u>ជាកម្មសិទ្ធិរបស់៖</u>

- បុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅពេលដាក់ពាក្យស្នើសុំ
- ពលរដ្ឋអាមេរិកឬអ្នករស់នៅអចិន្ត្រៃយ៍

## តើកម្មវិធីនេះនឹងត្រូវចាប់ផ្តើមបើកនៅពេលណា?

កម្មវិធីជំនួយនេះនឹងចាប់ផ្តើមបើកនៅថ្ងៃទី 15 ខែមិថុនាឆ្នាំ 2021 ។នេះគឺជាការដាក់ពាក្យជាដំណាក់កាលដោយការដាក់ពាក្យស្នើសុំជំនួយថវិកានឹងត្រូវបានត្រួតពិនិត្យជារៀងរាល់ខែ។អ្នកដាក់ពាក្យស្នើសុំអាចរំពឹងថានឹងទទួលដំណឹងមកវិញក្នុងរយៈពេលប្រាំមួយសប្តាហ៍បន្ទាប់ពីការដាក់ពាក្យស្នើសុំជំនួយថវិកាបានបញ្ចប់ រួមទាំងឯកសារនិងព័ត៌មានបន្ថែមចាំបាច់ទាំងអស់។

## តើខ្ញុំដាក់ពាក្យស្នើសុំដោយរបៀបណា?

អ្នកដាក់ពាក្យទាំងអស់ត្រូវតែទទួលបានការឧបត្ថម្ភពីអ្នកផ្តល់ជំនួយបច្ចេកទេសតាមរយៈកម្មវិធី SBTA របស់ MGCC ។សម្រាប់តារាងឈ្មោះអ្នកផ្តល់សេវាកម្ម SBTA របស់យើងសូមចុចត្រង់នេះ៖
https://www.empoweringsmallbusiness.org/fy2021-awardees

នៅពេលដែលអ្នកដាក់ពាក្យស្នើសុំមានអ្នកឧបត្ថម្ភ SBTA ពួកគេត្រូវតែឆ្លងកាត់ការវាយតម្លៃឌីជីថលដើម្បីវាយតម្លៃអំពីតម្រូវការឌីជីថលរបស់ពួកគេ។បន្ទាប់មកទៀត អ្នកដាក់ពាក្យស្នើសុំនឹងស្វែងរកអ្នកជំនាញដែលមានសមត្ថភាពដើម្បីរៀបចំគម្រោងអភិវឌ្ឍនសមត្ថភាពឌីជីថលរបស់ពួកគេ - ជាពិសេសនៅក្នុងផ្នែកនៃប្រតិបត្តិការ (នៅលើឌីជីថល) ពាណិជ្ជកម្មតាមរយៈអេឡិចត្រូនិច ទីផ្សារឌីជីថល និងការទាក់ទងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងបំពេញពាក្យស្នើសុំពេញលេញមួយតាមរយៈ Submittable ដោយមានការណែនាំពីអ្នកឧបត្ថម្ភ SBTA របស់ពួកគេនិងធនធានដែលផ្តល់ដោយ MGCC ។

MGCC នឹងផ្តល់ជំនួយថវិការហូតដល់ $5,000 សម្រាប់គម្រោងអភិវឌ្ឍន៍ឌីជីថលដែលបានបង់ទៅឱ្យអ្នកឧបត្ថម្ភ SBTA ប្រសិនបើមានការអនុម័តយល់ព្រម។ក្នុងចំណោមថវិកាជំនួយដែលទទួលបាននោះ $250

នឹងត្រូវបង់ទៅដល់អ្នកឧបត្ថម្ភ SBTA ។អ្នកឧបត្ថម្ភ SBTA អាចលះបង់ថ្លៃសេវានេះសម្រាប់អ្នកដាក់ពាក្យស្នើសុំតាមឆន្ទៈរបស់គេ។

សូមស្វែងរកឯកសារ RFP ពេញលេញ ព័ត៌មានបន្ថែមអំពីការដាក់ពាក្យ លក្ខខណ្ឌប្រើប្រាស់ថវិកាដែលបានអនុម័តយល់ព្រម និងព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័ររបស់យើង៖

https://www.empoweringsmallbusiness.org/empowerdigital